# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

<u>សេចក្តីប្រកាសពត៌មាន</u>

## ទីក្រុងមែលប៊ននឹងទទួលការបញ្ចាំងកម្មវិធីសិល្បៈ លំដាប់ពិភពលោក( World Premiere) បង្សុកូល៖ ស្មូតខ្មែរ

ទីក្រុងមែលប៊ននៃប្រទេសអូស្ត្រាលីមានកិត្តិយសទទួលបញ្ចាំងនូវកម្មវិធីសិល្បៈពិភពលោក World Premiere នៃការសម្តែង *បង្សុកូល៖ ស្មូតខ្មែរ* នៅខែតុលា ឆ្នាំ២០១៧។

ការប្រកាសនេះត្រូវបានធ្វើឡើងនៅថ្ងៃនេះ នៅឯសន្និសីទកាសែតនារាជធានីភ្នំពេញ ដែលមានការចូលរួមដោយលោកជំទាវឯកអគ្គរាជទូតអូស្ត្រាលី **អេនជេលឡា ខកខឺរ៉េន**។

បង្សុកូលគឺជាស្នាដៃស្មូតដ៏ធំមួយលើកដំបូងបំផុតដែលបកស្រាយអំពីរយៈពេលជាច្រើនឆ្នាំក្រោមរបបខ្មែរក្រហមនិងផលវិបាកក្រោយរបបនេះ។ ស្នាដៃនេះបានបញ្ចូលនូវ តន្ត្រី សម្លេង ភាពយន្ត និងកាយវិការ ហើយជាស្នាដៃរួមគ្នាជាលើកដំបូងរវាងអ្នកសរសេរភ្លេងដ៏ល្បីរបស់កម្ពុជាលោក **ហ៊ឹម សុភី** និងផលិតករភាពយន្តដ៏ឆ្នើមរបស់កម្ពុជាលោក **ឬទ្ធី ប៉ាន**។

«បង្សុកូល នឹងនាំសាច់រឿងរបស់កម្ពុជាឆ្ពោះទៅកាន់ទស្សនិកជនអូស្ត្រាលី។ វានឹងពង្រីកការការយល់ដឹងនិងកោតសរសើរនូវវប្បធម៌និងប្រវត្តិសាស្ត្រកម្ពុជា។ ហើយវាជាគំរូបង្ហាញនូវសិល្បៈ និងតន្ត្រីដែលល្អផ្តាច់គេរបស់កម្ពុជាលើឆាកអន្តរជាតិ។» បើតាមប្រសាសន៍លោកជំទាវ ខកខឺរ៉េន។

តាមរយៈបង្សុកូល ទំនាក់ទំនងរវាងប្រជាជនអូស្ត្រាលីនិងកម្ពុជាកំពុងតែពង្រឹងកាន់តែរឹងមាំជាបន្ថែមទៀត។

អ្នកបង្កើតចង្វាក់រាំអូស្ត្រាលីលោក Giden Obarzanek បានដើរតួនាទីយ៉ាងសំខាន់ក្នុងការផលិតស្នាដៃបង្សុកូលនេះ។

ការចាក់បញ្ចាំងនៅទីក្រុងមែលប៊នក៏នឹងពង្រីកការប្រាស្រ័យទាក់ទងជាមួយសហគមន៍ខ្មែរនៅអូស្ត្រាលីផងដែរ។

រដ្ឋាភិបាលអូស្ត្រាលីជាអ្នកឧបត្ថម្ភដ៏មានមោទនភាពចំពោះស្នាដៃបង្សុកូល ហើយយើងបានសហការយ៉ាងជិតស្និទជាមួយ Cambodian Living Arts ដើម្បីនាំយកស្នាដៃនេះទៅបញ្ចាំងក្នុងកម្មវិធី World Premiere នៅប្រទេសអូស្ត្រាលី។

លោកជំទាវឯកអគ្គរាជទូតបានបន្ថែមថា «អូស្ត្រាលីនឹងរង់ចាំស្វាគមន៍សិល្បៈករ ផលិតករ និងអ្នកគាំទ្រស្នាដៃបង្សុកូលមកកាន់ទីក្រុងដល់ស្រស់ឆើតរបស់យើង មែលប៊ន ដែលជាការបង្ហាញដ៏គួរឲ្យកត់សម្គាល់នៃការផ្លាស់ប្តូរនូវវប្បធម៌និងតន្ត្រីរវាងប្រទេសយើងទាំងពីរ។»

**ទំនាក់ទំនងពត៌មាន៖** Australian.Embassy.Cambodia@dfat.gov.au

**ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៧**